# របាយការណ៍ប្រចាំឆមាសទី១ ឆ្នាំ ២០១៧ របស់នាយកដ្ឋានផ្លូវលំជនបទ

## I. ការងាររដ្ឋបាល

### ក. ស្ថានភាពមន្ត្រីរាជការ

| | |
|---|---|
| - មន្ត្រីរាជការសរុប | ចំនួន ៧៧ នាក់ ( នារី ១១ នាក់) |
| - មន្ត្រីក្របខណ្ឌ | ចំនួន ៦១ នាក់ ( នារី ១០ នាក់) |
| - មន្ត្រីកំពុងធ្វើកម្មសិក្សា | ចំនួន ១៤ នាក់ ( នារី ០១ នាក់) |
| - មន្ត្រីជាប់កិច្ចសន្យា | ចំនួន ០២ នាក់ |
| - មន្ត្រីអវត្តមានសរុប | ចំនួន ០៧ នាក់ |
| ○ មន្ត្រីអវត្តមានមានមូលហេតុ | ចំនួន ០៧ នាក់ |
| - លោក សុច ថេន | ប្រចាំការដ្ឋាន |
| - លោក ភិន អភិរក្ស | ប្រចាំការដ្ឋាន |
| - លោក អៀង កាណាល់ | សម្រាកព្យាបាលជំងឺ |
| - លោកស្រី ទូច សម្ផស្ស | លំហែមាតុភាព |
| - លោក ឈុន ចំរើន | ចូលរួមវគ្គបណ្តុះបណ្តាលប្រទេសនូវែលហ្សេឡង់ |
| - កញ្ញា វ៉ន សិដ្ឋា | ចូលរួមវគ្គបណ្តុះបណ្តាលប្រទេសនូវែលហ្សេឡង់ |
| - លោក ផេង សំបូរ | ចូលរួមសិក្ខាសាលានៅប្រទេសចិន |
| - មន្ត្រីកំពុងបម្រើការងារនៅក្នុងគម្រោង | ចំនួន ២៣ នាក់ ( នារី ០៨ នាក់) |

### ខ. លិខិត និងឯកសារ

| | |
|---|---|
| - ទទួលលិខិតចូលពីក្រៅក្រសួង ស្ថាប័ននានា | ចំនួន ១០១ ច្បាប់ |
| - ទទួលលិខិតចូលពីក្រសួង និងនាយកដ្ឋាន | ចំនួន ២០៧ ច្បាប់ |
| - ប្រភេទលិខិតចេញ | ចំនួន ២៧៣ លេខ |
| - ប្រភេទលិខិតបញ្ជាបេសកកម្ម | ចំនួន ១៦៩ លេខ |
| - ប្រភេទលិខិតអញ្ជើញ | ចំនួន ១៣ លេខ |
| - ប្រភេទលិខិតអនុញ្ញាតច្បាប់ | ចំនួន ០៨ លេខ |

### គ. ការងារកិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាល

១- ចូលរួមប្រជុំ ចំនួន ២៥ លើក

២- ចូលរួមវគ្គបណ្តុះបណ្តាល ចំនួន ០៥ លើក

៣- ចូលរួមសិក្ខាសាលា ចំនួន ០៨ លើក

៤- ផ្សេងៗ ចំនួន ០៧ លើក ។

## II. ការងារបច្ចេកទេស

### ក. ការងារប្រើប្រាស់ថវិកាជំពូក២១

#### ១- ការងារសាងសង់ ជួសជុលផ្លូវ និងសំណង់សិល្បការ្យ

- គម្រោងសាងសង់ ជួសជុលផ្លូវ និងសំណង់សិល្បការ្យ ឆ្នាំ២០១៧ មាន ៦៧ គម្រោង បានកំពុងដំណើរការការដ្ឋានចំនួន ៤៣ គម្រោង លទ្ធផលគិតជាមធ្យមស្មើនឹង ៤៥ % ។

**២- ការងារចុះត្រួតពិនិត្យ វាយតម្លៃ និងចរចារថ្លៃ**

- ចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចុះត្រួតពិនិត្យ វាយតម្លៃបញ្ចប់សុពលភាព បានចំនួន ០៨ គម្រោង លើការងារ÷
  - ស្ថាបនាផ្លូវក្រាលកៅស៊ូ DBST ចំនួន ០១ ខ្សែ ប្រវែង ៥.២ គ.ម
  - ស្ថាបនាផ្លូវក្រាលក្រួសក្រហម ចំនួន ០៧ ខ្សែ ប្រវែងសរុប ១០២.៥៦៨ គ.ម
  - ស្ថាបនាផ្លូវក្រាលកម្ទេចថ្មភ្នំ និងល្បាយខ្សាច់ទន្លេ ចំនួន ០២ ខ្សែ ប្រវែងសរុប ១២.៦ គ.ម
  - សាងសង់ស្ពានបេតុង ចំនួន ១៤ កន្លែង
  - សាងសង់លូមូល ចំនួន ៧៤ កន្លែង និងលូប្រអប់ ចំនួន ១៤ កន្លែង
  - ស្ថាបនាផ្លូវក្រួសក្រហមសងខាងក្បាលស្ពាន ប្រវែង ១៥០ ម
  - លូបង្ហៀរទឹក ចំនួន ០១ កន្លែង
  - តម្លើងបង្គោលសុវត្ថិភាព ចំនួន ០៦ កន្លែង និងស្លាកឈ្មោះគម្រោង ចំនួន ០៦ កន្លែង
- ចូលរួមចរចារថ្លៃជាមួយគណៈកម្មាការអន្តរក្រសួង បានចំនួន ១៣ គម្រោង លើការងារ÷
  - ស្ថាបនាផ្លូវក្រាលក្រួសក្រហម ចំនួន ០៦ ខ្សែ ប្រវែងសរុប ៩៥.២ គ.ម
  - ស្ថាបនាផ្លូវក្រាលកៅស៊ូ DBST ចំនួន ០៣ ខ្សែ ប្រវែងសរុប ១៨ គ.ម
  - ផ្លូវក្រាលល្បាយភ្នំ និងល្បាយកម្ទេចភ្នំ ចំនួន ០២ ខ្សែ ប្រវែងសរុប ១៥ គ.ម
  - សាងសង់លូមូល ចំនួន ៤៧ កន្លែង, លូប្រអប់ ១២ កន្លែង និងស្លាកឈ្មោះ ០៦ កន្លែង
  - ស្ពានបេតុង ចំនួន ០៣ កន្លែង ប្រវែងសរុប ៦០ ម៉ែត្រ ។

**ខ. ការងារប្រើប្រាស់ថវិកាជំពូក៦១**

**១- ការងារថែទាំផ្លូវលក្ខណៈខួប ប្រចាំ និងជួសជុលបន្ទាន់**

- **ការងារថែទាំផ្លូវលក្ខណៈខួប÷** គម្រោងថែទាំផ្លូវលក្ខណៈខួប សម្រាប់ឆ្នាំ២០១៧ មានចំនួន ២៥ គម្រោង ស្មើនឹង ៨២ ខ្សែ ប្រវែសរុប ៤៩៧,១៦៤ គ.ម លូមូល ១០៤ កន្លែង និងលូប្រអប់ ០៥ កន្លែង។ កំពុងដំណើរការការដ្ឋានបានចំនួន ២២ គម្រោង លទ្ធផលគិតជាមធ្យម ៥៣ %។
- **ការងារថែទាំផ្លូវលក្ខណៈប្រចាំ÷** គម្រោងថែទាំផ្លូវលក្ខណៈប្រចាំ សម្រាប់ឆ្នាំ២០១៧ មានចំនួន ២៥ គម្រោង ស្មើនឹង ១៦១ ខ្សែ ប្រវែសរុប ១៥៧២,៦១ គ.ម និងស្លាកសញ្ញាចរាចរចំនួន ១០៦៧ ស្លាក។ កំពុងដំណើរការការដ្ឋានបានចំនួន ១៣ គម្រោង លទ្ធផលគិតជាមធ្យម ២១ %។

**២- ការងារចុះត្រួតពិនិត្យ វាយតម្លៃ និងសិក្សា**

- ចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចុះត្រួតពិនិត្យ វាយតម្លៃសុពលភាពការងារថែទាំផ្លូវខួប
  - ផ្លូវក្រាលក្រួសក្រហម ប្រវែង ៧ ៥០០ ម ស្ថិតនៅសង្កាត់កូនក្រៀល ក្រុងសំរោង
  - ផ្លូវក្រាលក្រួសក្រហម ប្រវែង ៨ ០០០ ម ស្ថិតនៅឃុំជើងទៀន ស្រុកចុងកាល់ ក្រុងសំរោង
  - ផ្លូវក្រាលក្រួសក្រហម ប្រវែង ១០ ៥០០ ម និងសាងសង់លូគ្រប់ប្រភេទចំនួន ០៧ កន្លែង ស្ថិតនៅឃុំសេដា ស្រុកលំផាត់ ខេត្តរតនគីរី

- ចុះពិនិត្យផ្លូវជួសជុលបន្ទាន់ជាមួយតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចំនួន ១៥ ខ្សែ ប្រវែងសរុប ៤៦.៤៥ គ.ម ស្ថិតនៅខេត្តស្វាយរៀង កណ្ដាល តាកែវ ព្រះសីហនុ កោះកុង ក្រចេះ មណ្ឌលគិរី ស្ទឹងត្រែង សៀមរាប រតនគិរី កំពត និងរាជធានីភ្នំពេញ
- ចុះពិនិត្យផ្លូវជួសជុលបន្ទាន់ជាមួយតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចំនួន ០៨ ខ្សែ ប្រវែងសរុប ៣០ គ.ម ស្ថិតនៅខេត្តក្រចេះ មណ្ឌលគិរី ស្ទឹងត្រែង សៀមរាប រតនគិរី កំពត
- ចុះសិក្សាផ្លូវកៅស៊ូ ប្រភេទ DBST សម្រាប់ដាក់ក្នុងគម្រោងថែទាំ ឆ្នាំ២០១៧ បានចំនួន ០៤ ខ្សែ ប្រវែងសរុប ១០២.៣២ គ.ម ខេត្តកំពង់ឆ្នាំង និងខេត្តត្បូងឃ្មុំ ។

**គ. សកម្មភាពការងារសហការជាមួយគម្រោង**

- ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីការគ្រប់គ្រងហានិភ័យអាកាសធាតុ និងការឆ្លើយតបដើម្បីសង្គ្រោះបន្ទាន់
- រៀបចំសំណើសុំគោលការណ៍ឯកភាព ប្រគល់បញ្ជីឈ្មោះកម្មករសាងសង់ ផ្លូវទៅអោយអ្នកម៉ៅការ ចំនួន ០៦ ខេត្ត គឺខេត្តតាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង សៀមរាប កំពង់ធំ និងខេត្តកំពង់ចាម ក្នុងគម្រោងកែលម្អផ្លូវជនបទ ជំហ៊ានទី២
- រៀបចំលិខិតប្រគល់ឯកសារបញ្ជីឈ្មោះកម្មករសាងសង់ផ្លូវ ទៅឱ្យក្រុមហ៊ុន Pyunghwa Engineering Consultants LTD ក្នុងគម្រោងកែលម្អផ្លូវជនបទ ជំហ៊ានទី២
- ចូលរួមផ្សព្វផ្សាយការទប់ស្កាត់ការរាលដាលដោយជំងឺអេដស៍ ជាមួយសហគមន៍តាមដងផ្លូវគម្រោងកែលម្អផ្លូវជនបទជំហាន២ ដែលរៀបចំឡើងដោយអង្គការ នៅខេត្តសៀមរាប និងខេត្តកំពង់ចាម
- ចុះត្រួតពិនិត្យផ្នែកយេនឌ័រ និងសុវត្ថិភាពសង្គមនៅលើខ្សែផ្លូវ ចំនួន ២១ ខ្សែ ក្នុងខេត្តត្បូងឃ្មុំ ពោធិ៍សាត់ បាត់ដំបង តាកែវ និងខេត្តបន្ទាយមានជ័យ ប្រវែងសរុប ៣៤៩.១៥ គ.ម
- ចុះផ្សព្វផ្សាយការលើកកម្ពស់ស្ត្រីឱ្យចូលរួមក្នុងការសាងសង់ផ្លូវជនបទជំហ៊ានទី២ ក្នុងគម្រោងកែលម្អផ្លូវជនបទ ផ្លូវចំនួន ០៤ ខ្សែ ក្នុងខេត្តបាត់ដំបង តាកែវ និងកោះចំនួន ០៥ ក្នុងខេត្តកំពង់ចាម ប្រវែងសរុប ៨៣.៥ គ.ម ។

**ប្រធាននាយកដ្ឋានផ្លូវលំជនបទ**